លេខ ១៧៥ ថ្ងៃពុធ ទី២១ ខែកញ្ញា ឆ្នាំ២០០៥

**ពត៌មានក្នុងប្រទេស**

# ព្រះមហាក្សត្រយាងប្រោសប្រទានព្រះរាជអំណោយដោយផ្ទាល់ ជូនប្រជារាស្ត្រ ២០០គ្រួសារ ដែលរងគ្រោះដោយទឹកជំនន់

*លោក ចង លីមអ៊ី AKP ភ្នំពេញ*

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អមព្រះរាជដំណើរដោយសម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង លោកជំទាវ ខែក ស៊ីសូដា ព្រះរាជពិធីការព្រះមហាក្សត្រ ព្រមទាំង ឯកឧត្តម លោក លោកស្រី ជាមន្ត្រីរាជការព្រះបរមរាជវាំងជាច្រើនរូបទៀតបានយាង និងអញ្ជើញចុះសាកសួរសុខទុក្ខ និងប្រោសព្រះរាជទានអំណោយជូនប្រជារាស្ត្រទីទ័លក្រ និងរងគ្រោះដោយទឹកជំនន់នៅភូមិឱម៉ាល់ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ កន្លងទៅនេះ ។

ក្នុងព្រះរាជដំណើរឆ្ពោះទៅកាន់ភូមិឱម៉ាល់ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម នាឱកាសនោះ ព្រះអង្គបានសព្វព្រះរាជហឫទ័យចុះសាកសួរសុខទុក្ខ និងប្រោសព្រះរាជទាននូវព្រះរាជអំណោយជូនក្រុមគ្រួសារកងនាវាចរចំនួន ៥០គ្រួសារ ដែលក្នុងមួយគ្រួសារទទួលបានអង្ករ ២០គ.ក្រ ឃីតមួយ ក្នុងនោះ មានសារុង១ ក្រមា១ ភួយ១ មុង១ និងថវិកាចំនួន ២០.០០០រៀល ។ បងប្អូនទាំងនោះរស់នៅតាមដងទន្លេសាប ។

បន្ទាប់ពីព្រះរាជសកម្មភាពសាកសួរសុខទុក្ខ និងប្រោសព្រះរាជទានអំណោយជូនក្រុមគ្រួសារកងនាវាចរដែលជួបការលំបាកក្នុងជីវភាពទាំងនោះរួចមក ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី និងប្រតិភូអមព្រះរាជដំណើរបានយាង និងអញ្ជើញបន្តព្រះរាជដំណើរតាមដងទន្លេសាបរហូតដល់ភូមិឱម៉ាល់ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម ហើយព្រះអង្គបានព្រះរាជទាននូវព្រះរាជអំណោយដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់ជូនដល់ប្រជារាស្ត្រទីទ័លក្រ និងកំពុងរងគ្រោះដោយសារទឹកជំនន់លិចផ្ទះសម្បែង ដីធ្លី ចំនួនសរុប ២០០គ្រួសារ ក្នុងរដូវវស្សានេះ ។

ក្នុងឱកាសនោះ ព្រះករុណា មានព្រះរាជហឫទ័យអាណិតអាសូរស្រឡាញ់ប្រជារាស្ត្រដ៏ជ្រាលជ្រៅព្រះអង្គបានប្រោសព្រះរាជទាននូវព្រះរាជអំណោយជូនប្រជារាស្ត្រនៅតាមផ្ទះ ដែលកំពុងលិចទឹកនីមួយៗដោយផ្ទាល់ព្រះហស្តតែម្តង ។ ព្រះរាជអំណោយដ៏ថ្លៃថ្លា ដែលប្រជារាស្ត្រកំពុងត្រូវការជាចាំបាច់នាឱកាសនោះ រួមមាន ក្នុង ១គ្រួសារ ទទួលបានអង្ករ ១០គីឡូក្រាម អំបិល ៤គីឡូក្រាម ត្រីខ ១០កំប៉ុង មី១០

កញ្ចប់ ត្រីងៀតកន្លះគីឡូ ឆៃប៉ូវកន្លះគីឡូ ទឹកត្រី ១ដប នំផុងកន្លះគីឡូ និងឃីតមួយ ដែលក្នុងនោះមាន មុង១ ក្រមា១ ភួយ១ សារុង១ ព្រមទាំងថវិកាចំនួន ២០.០០០រៀល ។

ប្រជារាស្ត្រដែលបានទទួលព្រះរាជអំណោយដោយផ្ទាល់នេះ បានសំដែងនូវក្តីសប្បាយរីករាយកោតសរសើរស្ញប់ស្ញែងយ៉ាងក្រៃលែងចំពោះព្រះករុណា ព្រះមហាក្សត្រកម្ពុជា ដែលព្រះអង្គបានយាងមកប្រោសប្រទានព្រះរាជអំណោយដោយផ្ទាល់ សូមបួងសួងថ្វាយព្រះអង្គបានជួបនូវព្រះពុទ្ធពរទាំង ៥ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។/

## លទ្ធផលនៃដំណើរទស្សនកិច្ចរបស់សម្តេច ហ៊ុន សែន នៅបារាំង

*លោក ជ័យ ភូមិពល AKP ភ្នំពេញ*

យោងប្រភពពីបរទេសឱ្យដឹងថាៈ កាលពីថ្ងៃច័ន្ទ ទី១៩ ខែកញ្ញា ឯ.ឧ ហ្សាក់ ស៊ីរ៉ាក់ ប្រធានាធិបតីបារាំង បានជួបសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការខិតខំប្រឹងប្រែង ដើម្បីនាំយកមេដឹកនាំនៃរបបខ្មែរក្រហមប្រល័យពូជសាសន៍ដែលនៅរស់យកទៅកាត់ទោស ។

ឯកឧត្តម ហ្សាក់ ស៊ីរ៉ាក់ បានមានប្រសាសន៍ម្តងទៀត អំពីការគាំទ្ររបស់បារាំង ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលត្រូវបានគេបន្ទោសថា បានសម្លាប់ប្រជាជនកម្ពុជាអស់ប្រហែល ២លាននាក់នៅក្នុងទសវត្ស ១៩៧០ ។

អ្នកនាំពាក្យរបស់ ឯ.ឧ ប្រធានាធិបតីបារាំង លោក ហ្សេរ៉ូម បូណាហ្វុង បាននិយាយថា ឯ.ឧ ប្រធានាធិបតីបារាំងបានសង្កត់ថា ការកាត់ទោសនេះ គឺជាការសំខាន់ ដើម្បីតស៊ូប្រឆាំងនឹងភាពគ្មានទោស និងជាការអភិវឌ្ឍន៍ដ៏គួរឱ្យចាប់អារម្មណ៍នៅក្នុងការធ្វើសហប្រតិបត្តិការវិស័យតុលាការរវាងរដ្ឋមួយ និងអង្គការសហប្រជាជាតិ ។

អ្នកនាំពាក្យរូបនេះ ក៏បាននិយាយផងដែរថា កិច្ចព្រមព្រៀងសហប្រតិបត្តិការមួយត្រូវបានគេរំពឹងថា នឹងចុះហត្ថលេខារវាងប្រទេសទាំងពីរ ដែលគ្របដណ្តប់ទៅលើវិស័យនានា ដូចជា វិស័យសុខាភិបាល វិស័យអប់រំ និងវិស័យយុត្តិធម៌ រហូតដល់ឆ្នាំ ២០១០ ។

រដ្ឋមន្ត្រីក្រសួងសហប្រតិបត្តិការបារាំង លោកស្រី ប្រីហ្សិត ហ្ស៊ីរ៉ាដាំង បានមានប្រសាសន៍នៅមុនពេលចុះហត្ថលេខាលើឯកសារជាមួយឧបនាយករដ្ឋមន្ត្រីកម្ពុជា ឯ.ឧ ហោ ណាំហុង ថា " នេះគឺជាជំហានថ្មីមួយនៅក្នុងកិច្ចសហប្រតិបត្តិការបារាំង-កម្ពុជា ហើយយើងទទួលខុសត្រូវបញ្ហានេះជាមួយគ្នា " ។

កិច្ចព្រមព្រៀងពីរទៀត ក៏ត្រូវបានចុះហត្ថលេខាផងដែរ គឺកិច្ចព្រមព្រៀងស្តីអំពីការអភិរក្សប្រាសាទអង្គរវត្ត និងការបង្កើតសកលវិទ្យាល័យថ្មីមួយ ដើម្បីសិក្សាអំពីការថែទាំសុខភាព ។

លោកស្រី រដ្ឋមន្ត្រីក្រសួងសហប្រតិបត្តិការបារាំង បានបន្ថែមថា " យើងបានព្រមព្រៀងដើម្បីប្រមូលផ្តុំជំនួយរបស់យើងនៅក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ នៅលើអាទិភាព ៣ ជាសំខាន់ ដែលជាបញ្ហាច្បាប់ និងជាទិសដៅនៃសហស្សវត្ស ( ជាពិសេសនៅក្នុងវិស័យកសិកម្ម សន្តិសុខនៃម្ហូបអាហារ បរិស្ថាន និងសុខាភិបាល ) ហើយនឹងចំណេះដឹង " ។

ចំណែក ឯ.ឧ ហោ ណាំហុង វិញ បានមានប្រសាសន៍ថា ប្រទេសកម្ពុជាមិនភ្លេចកិច្ចព្រមព្រៀងទីក្រុងបារីស ដែលបានចុះហត្ថលេខានៅក្នុងឆ្នាំ១៩៩១ ទៅតាមគំនិតផ្តួចផ្តើមរបស់បារាំងនោះទេ ដែលបានបញ្ចប់សង្គ្រាម ២០ឆ្នាំនោះ ។ ឯ.ឧ ហោ ណាំហុង បានបន្ថែមថា ប្រទេសកម្ពុជាមិនភ្លេចការគាំទ្ររបស់បារាំងនៅក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នោះឡើយ ។

ប្រទេសកម្ពុជាបានទទួលជំនួយពីសាធារណរដ្ឋបារាំងនៅក្នុងឆ្នាំ ២០០៥ សំរាប់អភិវឌ្ឍន៍ប្រទេសមានតំលៃជាង ២០លានអឺរ៉ូ ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងត្រូវជួបជាមួយពួកមេដឹកនាំពាណិជ្ជកម្មបារាំងនៅថ្ងៃអង្គារនៅមុនពេលសម្តេចវិលត្រឡប់មកប្រទេសវិញនៅក្នុងថ្ងៃ ពុធ នេះ ។

សម្តេច ហ៊ុន សែន បានអញ្ជើញទៅដល់ប្រទេសបារាំង កាលពីថ្ងៃ សៅរ៍ បន្ទាប់ពីសម្តេចបានចូលរួមនៅក្នុងកិច្ចប្រជុំកំពូលពិភពលោកនៅអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៦ ខែកញ្ញា នេះមក ។

ប្រទេសបារាំងរំពឹងថា នឹងទទួលស្វាគមន៍សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃប្រទេសកម្ពុជា នៅឆ្នាំ ២០០៦ នៅក្នុងប្រទេសបារាំង ។/

## សេចក្តីថ្លែងការណ៍
## របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងឱកាសប្រារព្ធពិធីអបអរសាទរ
## រំលឹកខួបលើកទី ៣ នៃទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ២០០៥

*-សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ*

*-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

*-បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា*

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្តេច ព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បងប្អូនជនរួមជាតិ និង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ភារធារី និងបណ្តាអង្គការអន្តរជាតិទាំងអស់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានចូលរួមសំដែងអំណរសាទររំលឹកខួបលើកទី ៣ *នៃទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ឆ្នាំ ២០០៥ នេះ* ។

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៥ គឺជាទិវាប្រកបដោយនក្ខត្តឫក្ស ស្ថិតក្នុងបរិយាកាសដ៏ល្អថ្លៃថ្លាមហាប្រសើរ ដែលរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងទូទាំងប្រទេស មានទឹកចិត្តសោមនស្សរីករាយប្រារព្ធពិធីដ៏មហោឡារិក អបអរសាទរយ៉ាងក្លៀវក្លាទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា លើកទី៣ រួមជាមួយប្រជាជនក្នុងទូទាំងសាកលលោក ។

ក្នុងឱកាសដែលយើងកំពុងប្រារព្ធរំលឹកខួបលើកទី៣ នៃទិវាសន្តិភាពអន្តរជាតិនេះ គឺស្របពេលដែលកម្ពុជាកំពុងត្រៀមលក្ខណៈរៀបចំខួបលើកទី១១ នៃទិវាប្រកាសបើកឱ្យប្រើប្រាស់ជាផ្លូវការរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា និងស្របពេលគ្នាដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងបន្តអនុវត្តយ៉ាងសស្រាក់សស្រាំនូវយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន ដើម្បីលើកកំពស់កំណើនការងារ សមធម៌ និងប្រសិទ្ធិភាពនៅកម្ពុជា សំដៅឈានឆ្ពោះទៅសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ វឌ្ឍនភាព វិបុលភាព សុខុដុមរមនា និងសុភមង្គល ជូនប្រជាជនកម្ពុជា ។

*-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

*-បងប្អូនជនរួមជាតិជាទីស្នេហា*

ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង អស់រយៈពេលរាប់ទសវត្សរ៍ ដោយឆ្លងកាត់គ្រោះថ្នាក់ ការលំបាក និងឧបស័គ្គតូចធំច្រើនរាប់មិនអស់ ដើម្បីស្តារ និងកសាងប្រទេសឡើងវិញ ពីការបំផ្លិចបំផ្លាញនៃរបបប្រល័យពូជសាសន៍ និងសង្គ្រាមរ៉ាំរ៉ៃរាប់សិបឆ្នាំ រហូតទទួលបាននូវសុខសន្តិភាពពេញលេញ និងស្ថេរភាពសេដ្ឋកិច្ចរឹងមាំ ។ ក្នុងនាមជាប្រទេសមួយដែលធ្លាប់ទទួលរងគ្រោះ និងមហន្តរាយដោយសារសង្គ្រាមជាច្រើនតំណាក់កាល ប្រជាជនកម្ពុជាយល់ច្បាស់អំពីសារៈសំខាន់ និងតម្លៃនៃសុខសន្តិភាព ។ ក្នុងន័យនេះ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវមនោសញ្ចេតនាប្រកបដោយកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និងស្មោះត្រង់ចំពោះអង្គការសហប្រជាជាតិ ដែលបានផ្តួចផ្តើមកំណត់យកថ្ងៃ ២១ កញ្ញា ជារៀងរាល់ឆ្នាំ ជាទិវាសន្តិភាពអន្តរជាតិ ដែលនេះគឺជាឆន្ទៈ និងជាសំណូមពរដ៏ទទូចជាអចិន្ត្រៃយ៍របស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាផងដែរ ។

គន្លងមក ក៏ដូចជាបច្ចុប្បន្ន ក្នុងឋានៈជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាតែងតែបានខិតខំបំពេញនូវកាតព្វកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងយ៉ាងសមស្រប ដើម្បីរួមចំណែកសំរេចនូវឧត្តមគតិដ៏ថ្លៃថ្លារបស់អង្គការសហប្រជាជាតិ គឺការថែរក្សាសន្តិភាព សន្តិសុខជាសកល និងការអភិវឌ្ឍន៍សង្គមសំរាប់មនុស្សជាតិទូទៅ ។ ជាក់ស្តែងក្នុងឱកាសប្រជុំលើកទី១ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង និងទប់ស្កាត់ភេរវកម្ម យើងបានគូសបញ្ជាក់យ៉ាងច្បាស់ថា ភេរវកម្មជាបញ្ហាអន្តរជាតិមួយ ដែលកម្ពុជាត្រូវតែចូលរួមយ៉ាងសកម្ម ទោះបីកម្ពុជាមិនមែនជាគោលដៅដ៏សំខាន់នៃពួកភេរវកម្មក៏ដោយ ។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា អំពើភេរវកម្មជាឧក្រិដ្ឋកម្មឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ដែលបង្កើតចលាចលដល់សង្គម និងបង្កមហន្តរាយដល់អាយុជីវិតមនុស្សគ្រប់ជាតិសាសន៍ គ្រប់ភេទ គ្រប់វ័យ គ្រប់ទីកន្លែង ។ ក្នុងន័យនេះ ច្បាស់ណាស់ថា បញ្ហាភេរវកម្ម គឺជាបញ្ហាសកល មិនមែនជាបញ្ហាដាច់ដោយឡែករបស់ប្រទេសណាមួយនោះទេ ហើយក៏ជាបញ្ហាអន្តរជាតិមួយ ដែលនៅក្នុងប្រទេសនិមួយៗត្រូវតែដោះស្រាយបញ្ហានេះ ត្រូវតែមានកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងក្របខ័ណ្ឌតំបន់ ឬអន្តរទ្វីប ទើបអាចដោះស្រាយបញ្ហាដ៏លំបាកស្មុគស្មាញនេះបាន ។

ខ្ញុំព្រះករុណា ខ្ញុំមានជំនឿថា ឆ្លងតាមបទពិសោធន៍ពីអតីតកាល និងឧបសគ្គថ្មីៗដែលកើតមានដល់មនុស្សជាតិកន្លងមក គំនិតផ្តួចផ្តើមកំណត់យកថ្ងៃទី ២១ ខែកញ្ញា ជាទិវាសន្តិភាពអន្តរជាតិរបស់អង្គការសហប្រជាជាតិ បានធ្វើឱ្យប្រជាជនលើសកលលោកដែលស្រឡាញ់សន្តិភាព ក៏ដូចជាប្រជាជនកម្ពុជាមានសេចក្តីសង្ឃឹម និងមានជំនឿជឿជាក់លើអនាគតភ្លឺស្វាង សេចក្តីសុខក្សេមក្សាន្ត ការរួមរស់ជាមហាគ្រួសារមួយ ប្រកបដោយសុភមង្គល និងការអភិវឌ្ឍន៍សំរាប់សង្គមមនុស្សដោយពិតប្រាកដ ។

ច្បាស់ណាស់ថា សម្រាប់ព្រះរាជាណាចក្រកម្ពុជា ការថែរក្សាសន្តិភាព ស្ថិរភាពនយោបាយឱ្យបានស្ថិតស្ថេរគង់វង្សជានិរន្តរ៍ គឺជាបំណងដ៏ពិសិដ្ឋរបស់ខ្លួន ហើយជានិច្ចកាលយើងប្តេជ្ញាបូជាអ្វីៗទាំងអស់ដើម្បីសេចក្តីសុខសាន្តរបស់ប្រជាពលរដ្ឋ ។ ខ្ញុំព្រះករុណា ខ្ញុំជឿជាក់ថា សន្តិភាពសម្រាប់មនុស្សជាតិមានតម្លៃខ្ពស់ណាស់ ដែលចាំបាច់ត្រូវរួមគ្នាថែរក្សាដោយស្មារតីអត់ធ្មត់ និងដោយប្រុងប្រយ័ត្ន ដើម្បីឱ្យសុខសន្តិភាពនេះមានអាយុកាលជាអមតៈ ។ ក្នុងក្របខណ្ឌនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើនូវអ្វីៗគ្រប់យ៉ាងដើម្បីសន្តិភាពពីក្នុងដួងចិត្តរហូតដល់សកម្មភាពប្រចាំថ្ងៃរបស់ខ្លួន ។ ជាក់ស្តែងមានជាអាទិ៍ ការចាត់វិធានការបំផ្លាញគ្រឿងអាវុធជាតិផ្ទុះជាបន្តបន្ទាប់ វិធានការប្រឆាំងអំពើភេរវកម្ម ឧក្រិដ្ឋកម្មគ្រប់ប្រភេទ វិធានការទប់ស្កាត់ និងលុបបំបាត់អំពើហិង្សា អំពើអនាចារ និងទុច្ចរិតតូចធំផ្សេងៗជាដើម ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាដោយឥតងាករេ និងបានបន្តខិតខំធ្វើពលីកម្មគ្រប់បែបយ៉ាងដើម្បីសន្តិសុខសម្រាប់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងសង្គមគ្រួសារនីមួយៗ និងក្នុងសង្គមជាតិ ព្រមទាំងក្នុងសន្តិសុខសង្គមមនុស្សជាតិក្នុងសកលលោកទាំងមូល ។ ជាការពិតដោយសារការប្តេជ្ញាចិត្តខ្ពស់នេះទើប

កន្លងមករាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវទិសដៅរបស់ខ្លួនដោយជោគជ័យ ។ ខ្ញុំព្រះករុណា ខ្ញុំសូមទាញអារម្មណ៍មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដើម្បីកត់សម្គាល់ថា កន្លងមកយើងបានអនុវត្តដោយជោគជ័យនូវយុទ្ធសាស្រ្តរបស់យើងជាបន្តបន្ទាប់ ជាពិសេសការថែរក្សាការពារស្ថិរភាពនយោបាយ សន្តិសុខសង្គម សេចក្ដីសុខសាន្តរបស់ប្រជាជន ដោយយើងបានអនុវត្តនូវនយោបាយ " ឈ្នះ! ឈ្នះ! " ដែលធ្វើឱ្យទឹកដីទាំងមូលទទួលបាននូវសុខសន្តិភាពពេញលេញ គ្មានតំបន់អបគមន៍ និងបានធ្វើឱ្យរលំរលាយទាំងស្រុងនូវអង្គការចាត់តាំងទាំងនយោបាយ និងយោធារបស់ពួកខ្មែរក្រហម ដែលជាសន្តិភាពពុំធ្លាប់ដែលកើតមានក្នុងប្រវត្តិសាស្រ្តដ៏យូរលង់នៅលើទឹកដីកម្ពុជា ។ ជាមួយគ្នានោះ ច្បាប់ស្តីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហមដោយផ្អែកលើជំហរមួយដ៏ជាក់លាក់ គឺកាត់ទោសខ្មែរក្រហមទៅតាមនីតិវិធីផង និងធានាការពារឱ្យបានយ៉ាងពេញលេញនូវស្ថិរភាព សន្តិភាព សេចក្ដីសុខសាន្តដល់ប្រជាពលរដ្ឋកម្ពុជាក្នុងទូទាំងប្រទេសផង នឹងត្រូវប្រព្រឹត្តទៅក្នុងពេលខាងមុខនេះ ។

រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជាជឿជាក់ថា អាស្រ័យដោយគំនិតផ្ដួចផ្ដើមដ៏ប្រពៃក្នុងការអនុវត្តន៍ទស្សនៈវិជ្ជាដ៏សំខាន់ គឺអហិង្សា គតិបណ្ឌិត និងកម្លាំងសាមគ្គីដ៏រឹងមាំ ឆន្ទៈស្មោះត្រង់ បំពេញភារកិច្ចនិងអនុវត្តជាក់ស្ដែងរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា រួមជាមួយបណ្ដាប្រទេសជាសមាជិកអង្គការសហប្រជាជាតិ យើងប្រាកដជានឹងសំរេចបានជោកជ័យថែមទៀត ក្នុងសកម្មភាពផ្ទើងឧត្តមគតិសន្តិភាព កាត់បន្ថយបានភាពតានតឹង បញ្ឈប់អំពើហិង្សា និងការប្រទូស្តរាយ ដែលបង្កឱ្យមានវិវាទ បញ្ឈប់បានការផ្ទុះអាវុធ គំរាមកំហែង និងធ្វើឱ្យភ័យខ្លាចដល់អាយុជីវិតរស់នៅរបស់មនុស្សជាតិ ព្រមទាំងថែរក្សាសន្តិភាព ស្ថិរភាពពិភពលោក លើមាគ៌ាអភិវឌ្ឍន៍សង្គមសំបូររុងរឿង ។

ក្នុងស្មារតីរក្សាសុខសន្តិភាព វឌ្ឍនភាព វិបុលភាព ភាពសុខុដុមរមនា និងសុភមង្គលជូនប្រជាជន រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាតែងតែចងចាំជានិច្ចនូវគុណូបការៈដ៏ថ្លៃថ្លារបស់អង្គការសហប្រជាជាតិ បណ្ដាអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនៃដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានរួមចំណែកក្នុងដំណើរស្វែងរកសន្តិភាព ហើយបាននិងកំពុងបន្តជួយឧបត្ថម្ភគាំទ្រទាំងស្មារតី សម្ភារៈ ថវិកា ក្នុងកិច្ចដំណើរការស្ដារ និងកសាងប្រទេសកម្ពុជាឡើងវិញ ។

ជាទីបញ្ចប់ ខ្ញុំព្រះរុណា ខ្ញុំសូមប្រគេនពរ ជូនពរ បវរមហាប្រសើរ ចំពោះសម្ដេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពរទាំង ៥ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសឱ្យស្មារតី ២១ កញ្ញា នៃទិវាសន្តិភាពអន្តរជាតិស្ថិតនៅជាអមតៈក្នុងចិត្តគំនិតរបស់មនុស្សជាតិគ្រប់រូប !

*សូមអរព្រះគុណ-សូមអរគុណ !*

# ឯកឧត្តម ស ខេង អញ្ជើញចុះចែកអំណោយជូនប្រជាពលរដ្ឋជួបប្រទះគ្រោះទឹកជំនន់ ចំនួន ៣២០គ្រួសារ ក្នុងឃុំព្រែកជីក ស្រុកមោងឫស្សី

*លោក ឡេង ហុក AKP បាត់ដំបង*

កាលពីព្រឹកថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ ឯ.ឧ ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជាអមដំណើរដោយលោកជំទាវ លី គឹមលាង តំណាងរាស្ត្រមណ្ឌលបាត់ដំបង ឯ.ឧ ប្រាជ្ញ ចន្ទ អភិបាលខេត្តបាត់ដំបង មន្ត្រីរាជការខេត្ត បានអញ្ជើញចុះចែកអំណោយដល់ប្រជាពលរដ្ឋ ដែលជួបប្រទះគ្រោះទឹកជំនន់ ស្ថិតក្នុងឃុំព្រែកជីក ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

លោក យឹន ថើយ ប្រធានក្រុមប្រឹក្សាឃុំព្រែកជីក បានឱ្យដឹងថា : នៅឃុំព្រែកជីកក្នុងរដូវវស្សានេះ បង្កបង្កើនផលស្រូវបានជាង ២៩៦០ហិកតា ដំណាំរួមផ្សំ ៣៤០ហិកតា ។ ឃុំនេះ មានប្រជាពលរដ្ឋរស់នៅ ២២៩៩គ្រួសារ មនុស្សមាន ១២.៩៥៣នាក់ ក្នុងនោះ ស្ត្រីមាន ៦.៣៨១នាក់ ចែកចេញជា ១០ភូមិ ក្នុងនោះ ៥ភូមិពេញសិទ្ធិ និង ៥ភូមិនៅបណ្តោះអាសន្ន ។

កាលពីថ្ងៃទី១៣ ទៅ ១៤ ខែកញ្ញា ឆ្នាំ២០០៥ មានភ្លៀងធ្លាក់ច្រើន បណ្តាលឱ្យលិច និងខូចខាតផ្ទះអស់ ៣២០ខ្នង ដាច់ផ្លូវ ៥កន្លែង ប្រវែង ៥៣០ម៉ែត្រ និងខូចខាតដំណាំរួមផ្សំស្ទើរតែទាំងស្រុង ។

ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា : បន្ទាប់ពីបានឮពត៌មានពី ឯ.ឧ ប្រាជ្ញ ចន្ទ អភិបាលខេត្តបាត់ដំបង ថា កាលពីថ្ងៃទី១៣-១៤ កញ្ញា មានភ្លៀងធ្លាក់យ៉ាងច្រើន បណ្តាលឱ្យទឹកជន់លិច នាំឱ្យខូចខាតដល់ផ្ទះសំបែងប្រជាពលរដ្ឋចំនួន ៣២០គ្រួសារ ព្រមទាំងខូចខាតអស់ផលដំណាំជាច្រើនទៀតនោះធ្វើឱ្យឯកឧត្តមមានទឹកចិត្តព្រួយបារម្ភ ចុះសួរសុខទុក្ខ និងនាំយកអំណោយទៅចែកជូនប្រជាពលរដ្ឋទាំងនោះឱ្យបានទាន់ពេលវេលា ។

ឯកឧត្តម ស ខេង បន្តទៀតថា: នេះគឺជាបទពិសោធន៍មួយល្អណាស់សំរាប់ប្រជាពលរដ្ឋ ដែលអាជ្ញាធរបានយកចិត្តទុកដាក់បានទាន់ពេលវេលា ចំពោះប្រជាពលរដ្ឋដែលកំពុងជួបប្រទះនូវការអត់ឃ្លាន ។

ឯកឧត្តម បានសំណូមពរឱ្យអាជ្ញាធរឃុំ ស្រុក ខេត្ត យល់ដឹងឱ្យបានច្បាស់ចំពោះប្រជាពលរដ្ឋដែលជួបប្រទះនូវការលំបាក ដូចជាគ្រោះទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ។ល។ ហើយត្រូវតាមដានជាប្រចាំ

នូវជម្ងឺ ឬការរអត់បាយ និងការងារបង្កបង្កើនផលបានតិច ឬច្រើនរបស់ប្រជាពលរដ្ឋ ដើម្បីរាយការណ៍ឱ្យទាន់សភាពការណ៍ ។ ជាចុងក្រោយ ឯ.ឧ ស ខេង នាយករដ្ឋមន្ត្រីស្ដីទី បានក្រើនរំលឹកដល់អាជ្ញាធរខេត្ត ស្រុក ខិតខំធ្វើយ៉ាងណានាំគ្នាដាំដើមឈើឱ្យបានច្រើន ដើម្បីធ្វើឱ្យបរិស្ថានបានល្អឡើងវិញ ។

គួរបញ្ជាក់ដែរថា ប្រជាពលរដ្ឋទាំង ៣២០គ្រួសារនោះ បានទទួលអំណោយក្នុងមួយគ្រួសារមានអង្ករ ៥០គ.ក្រ ខោអាវ ២កំប្លេរ មុង១ ភួយ១ ក្រមា១ សាប៊ូ ២ដុំ ម្សៅសាប៊ូចំនួនកន្លះគីឡូក្រាមផងដែរ ។/

# គណៈស្ថាបត្យករនៃព្រះរាជាណាចក្រកម្ពុជា នឹងក្លាយជាសេនាធិការសំរាប់រាជរដ្ឋាភិបាលនាពេលខាងមុខ

*លោក អ៊ុក សាផាន AKP ភ្នំពេញ*

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីនៅក្នុងពិធីបិទសិក្ខាសាលាស្ដីពី " គណៈស្ថាបត្យករនៃព្រះរាជាណាចក្រកម្ពុជា " នារសៀលថ្ងៃទី២០ កញ្ញា ២០០៩ នៅសាលាភូមិន្ទរដ្ឋបាល ។

អង្គសិក្ខាសាលានេះ បានដំណើរការពេញ ១ថ្ងៃ ដោយមានការអញ្ជើញចូលរួមពីនិស្សិតផ្នែកស្ថាបត្យករមកពីគ្រប់មហាវិទ្យាល័យរដ្ឋ និងឯកជន ស្ថាបត្យករជាច្រើនរូបទៀត ។ អង្គសិក្ខាសាលាក៏មានការរៀបចំតាំងពិពណ៌គំរោងប្លង់ជាច្រើន បែបបូរាណ និងសម័យ ដែលជាស្នាដៃរបស់និស្សិត និងស្ថាបត្យករខ្មែរយើង ។

មន្ត្រីជាន់ខ្ពស់កម្ពុជា ក៏ដូចជាភ្ញៀវដែលបានអញ្ជើញចូលរួម ពិសេសឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន បានកោតសរសើរ និងវាយតំលៃខ្ពស់ចំពោះស្នាដៃគំរោងប្លង់ដ៏ល្អៗ ប្រណិតៗតាមរចនាបទខ្មែរ និងមួយចំនួនជាប្លង់ទំនើបទាន់សម័យបច្ចុប្បន្ន និងទៅអនាគត ។

ក្នុងពិធីបិទសិក្ខាសាលានេះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានថ្លែងនូវការកោតសរសើរចំពោះស្ថាបត្យករទាំងអស់ដែលបានចូលរួម និងឯកភាពគ្នាបង្កើតគណៈស្ថាបត្យករនៃព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តម សុខ អាន មានប្រសាសន៍ថា ស្ថាប័ននេះ ជាស្ថាប័នឯករាជ្យមួយ ដែលនឹងក្លាយទៅជាសេនាធិការនាពេលខាងមុខ សំរាប់ជំនាញស្ថាបត្យកម្មរបស់រាជរដ្ឋាភិបាល ។ ការបង្កើតស្ថាប័នថ្មីនេះ គឺត្រឹមត្រូវ និងទាន់ពេលវេលា នៅពេលដែលបណ្ដាប្រទេសនានា នៅលើសកលលោកមួយចំនួនកំពុងទន្ទឹងរង់ចាំ ដើម្បីចូលរួមធ្វើសហប្រតិបត្តិការខាងមុខជំនាញស្ថាបត្យកម្មជាមួយស្ថាបត្យករ នៃព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានលើកឡើងថា បច្ចុប្បន្នមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយកម្មវិទ្យា បានបណ្តុះបណ្តាលស្ថាបត្យកររាប់រយនាក់ ដែលជាតម្រូវការចាំបាច់សម្រាប់ការស្តារ និងកសាងប្រទេសឡើងវិញ ។ យើងសង្កេតឃើញថា ការបណ្តុះបណ្តាលលើជំនាញស្ថាបត្យកម្ម និងនគរូបនីយកម្មក៏មានការរួមចំណែកយ៉ាងសកម្មពីផ្នែកឯកជនផងដែរ ។ ស្ថាបត្យករមួយចំនួនបានបញ្ចេញស្នាដៃរបស់ខ្លួនលើបណ្តាសំណង់ប្រណិតៗ មានទិដ្ឋភាពស្ថាបត្យកម្មសម័យទំនើប និងមានរចនាបទខ្មែរគួរឱ្យចាប់អារម្មណ៍ ដែលផ្តល់នូវផាសុខភាព និងសម្រស់ទៀតផង ។

ឯកឧត្តម បន្តថា : យើងនៅមានបញ្ហាប្រឈម និងបន្ទុកកិច្ចការជាច្រើនទៀតត្រូវធ្វើ ចាំបាច់យើងត្រូវបង្កើតសមត្ថភាពយល់ដឹង ទទួលស្គាល់ភាពខ្វះខាត និងទទួលយកបទពិសោធន៍ល្អៗថែមទៀតខាងមុខជំនាញស្ថាបត្យកម្ម នគរូបនីយកម្មពីក្រៅប្រទេស ។ ទិដ្ឋភាពខាងផ្នែកស្ថាបត្យកម្មខ្លះបានជះឥទ្ធិពលមិនល្អដល់ការរស់នៅ បង្កើតឱ្យមានភាពអាណាធិបតេយ្យទាំងផ្នែកស្ថាបត្យកម្ម និងនគរូបនីយកម្មព្រមទាំងការរៀបចំនានា ។ អាជ្ញាធរមានសមត្ថកិច្ចមួយចំនួន ដែលមានភារកិច្ចចុះទៅត្រួតពិនិត្យការដ្ឋានសាងសង់តាមដំណាក់កាលនីមួយៗខ្វះការទទួលខុសត្រូវ ហើយឃុបឃិតជាមួយម្ចាស់សំណង់ ពុំគោរពតាមគំរោងប្លង់ដែលស្ថាប័នផ្តល់លិខិតអនុញ្ញាត និងច្បាប់សាងសង់នោះ ប៉ះពាល់ដល់បរិស្ថាន និងសេវាសាធារណ: ។

ឯកឧត្តម សុខ អាន បន្តទៀតថា នេះជាឱកាសដ៏ល្អដែលរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់បង្កើតគណ:ស្ថាបត្យករនេះឡើង ដែលជាស្ថាប័នមួយឯករាជ្យ បង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងដំណើរការវិវត្តន៍វិស័យស្ថាបត្យកម្ម និងនគរូបនីយកម្មនៅកម្ពុជា ដែលកំពុងមានសន្ទុះរីកចំរើនយ៉ាងលឿន និងទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ សំដៅធានាឱ្យបាននូវតុល្យភាពនៃការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសណ្តាប់ធ្នាប់សំណង់ ។ គណ:ស្ថាបត្យករក៏មានតួនាទីគិតដល់កត្តាគុណភាពជាស្នូល និងគិតគូការងារជូនដល់ស្ថាបត្យករផងដែរ ។/

## ដំណាំអំពៅក្នុងឆ្នាំនេះ មានតម្លៃថោកជាងកាលពីឆ្នាំទៅ

*AKP កំពង់ចាម*

អំពៅជាដំណាំបន្ទាប់បន្សំរបស់ខេត្តកំពង់ចាមបន្ទាប់ពីដំណាំស្រូវ និងកៅស៊ូមក ។ ក្នុងចំណោមស្រុកទាំង ១៦ របស់ខេត្តកំពង់ចាម មានតែស្រុក ៣ប៉ុណ្ណោះ ដែលគ្មានដំណាំអំពៅ គឺស្រុកក្រូចឆ្មារ ស្រុកបាធាយ និងស្រុកអូររាំងឪ ។

មន្ត្រីមន្ទីរកសិកម្មខេត្តបានឱ្យដឹងថា ៖ កាលពីឆ្នាំទៅ អំពៅទូទាំងខេត្តឱ្យផលបានជាងពីរម៉ឺនតោន លើផ្ទៃដីដាំដុះប្រមាណ ១.១៣២ហិកតា ។

លោក សេង យុយ មេឃុំអង្គរបាន ឱ្យដឹងថា ៖ ដោយឡែកកសិករក្នុងឃុំរបស់លោកនិយមដាំអំពៅនៅក្នុងខែកុម្ភៈ ដើម្បីទទួលនៅចុងខែកក្កដា រហូតដល់ខែតុលា បន្ទាប់មកកសិករធ្វើស្រែប្រដេញទឹកលើដីនោះបន្តទៀត ។ អំពៅបានជួយសំរាលជីវភាពរបស់ប្រជាពលរដ្ឋនៅពេលដែលស្រូវរបស់គាត់ស្កកពិសេសក្នុងឆ្នាំនេះ ។

លោក កាន់ គន់លី មេឃុំជប់ ស្រុកត្បូងឃ្មុំ លោកមានជំនាញខាងដាំអំពៅ ដូចប្រជាកសិករផ្សេងទៀតដែរ លោកបានឱ្យដឹងថា ៖ ក្នុងដីមួយហិកតាគេអាចដាំអំពៅបានមួយម៉ឺនគុម្ព ដោយក្នុងមួយគុម្ពមាន ៤ដើម (៤ដើម) អំពៅត្រូវការជី នឹងទឹកជាចាំបាច់ ។

ជាមធ្យម អ្នកដាំអំពៅបានចំណាយជាងមួយលានរៀលសំរាប់ការដាំដុះលើផ្ទៃដីមួយហិកតា ប៉ុន្តែដល់ពេលប្រមូលផល គឺបានមកវិញចំនួន ២ ឬ ៣ដង នៃតម្លៃដើម ។

អំពៅ ២ប្រភេទ ដែលគេនិយមដាំនៅក្នុងខេត្តកំពង់ចាម គឺអំពៅត្រែង និងអំពៅស្ករ ។ អំពៅត្រែងលក់បានថ្លៃជាងអំពៅស្ករ ដោយសារវាស្វិត មិនងាយបាក់ដូចអំពៅស្ករទេ ដែលអ្នកគាបទឹកអំពៅលក់ចូលចិត្តទិញ ។ ក្នុងពេលដែលអំពៅស្ករមានតម្លៃមួយបាច់ ១.៥០០រៀល អំពៅត្រែងតម្លៃ ៤.០០០ រៀល ។

កសិករដែលរស់នៅតាមដងទន្លេ អាចដាំអំពៅបានទាំងរដូវប្រាំង និងរដូវវស្សា រីឯប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ខ្ពង់រាបវិញ ដាំអំពៅតែរដូវប្រាំងប៉ុណ្ណោះ ។

អំពៅជាទូទៅគ្រាន់តែសំរាប់បំរើការហូបចុកប៉ុណ្ណោះ ដូចជាធ្វើជាអំពៅសាង ឬកាត់កង់ប្រវែង ៣ ឬ ៤តឹក សំរាប់លក់ ជាពិសេសជាងនេះទៅទៀត គឺគាបយកទឹក ។

លោក ហាក់ យន អនុប្រធានការិយាល័យក្សេត្រសាស្ត្រ និងកែលំអដីរបស់មន្ទីរកសិកម្មខេត្តកំពង់ចាម បានឱ្យដឹងថា ៖ មានអ្នកវិនិយោគទុនម្នាក់កំពុងសិក្សាអំពីលទ្ធភាពបង្កើតរោងចក្រផលិតស្ករសដែលនឹងអាចបោះទីតាំងនៅក្នុងស្រុកព្រៃឈរ ។ កិច្ចការនេះតម្រូវឱ្យមានការសិក្សាច្បាស់លាស់ជាមុនសិនថា តើដំណាំអំពៅរបស់ប្រជាកសិករយើងនេះ អាចផ្គត់ផ្គង់ដល់ដំណើរការរោងចក្ររបស់គេបានគ្រប់គ្រាន់ ឬយ៉ាងណា ។/

## CMAC **បណ្តុះបណ្តាលប្រជាពលរដ្ឋក្រីក្រនៅតាមសហគមន៍ឱ្យចេះដោះមីន**

*លោក ជ័យ ភូមិពល AKP ភ្នំពេញ*

ឯកឧត្តម ខឹម សោភ័ណ អគ្គនាយក CMAC បាននិយាយឱ្យដឹងថា CMAC នឹងធ្វើការបណ្តុះបណ្តាលប្រជាពលរដ្ឋក្រីក្ររស់នៅតាមសហគមន៍បន្ថែមទៀត ពិសេសស្ត្រីឱ្យចេះអំពីរបៀបដោះមីន ដើម្បីឱ្យពួកគេចូលរួមបោសសំអាតមីននៅតាមភូមិ ឃុំរបស់ពួកគេ ។

គំរោងបណ្តុះបណ្តាលប្រជាពលរដ្ឋក្រីក្រនៅតាមសហគមន៍ឱ្យចេះដោះមីននេះ បានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៣ ដែលរហូតមកទល់ពេលនេះ CMAC បានធ្វើការបណ្តុះបណ្តាលស្ត្រីបានចំនួន ១៨នាក់ និងបុរសចំនួន ១៨នាក់ ដែលពួកគេទាំងនេះ មកពីស្រុកកំរៀង ខេត្តបាត់ដំបង ។ នៅឆ្នាំនេះ CMAC នឹងជ្រើសរើសនៅខេត្តព្រះវិហារចំនួន៣០នាក់ មកធ្វើការបណ្តុះបណ្តាលបន្ថែមទៀត ។ លោកអគ្គនាយក CMAC និយាយថា បើមានថវិកាគ្រប់គ្រាន់ CMAC នឹងជ្រើសរើសនៅស្រុកមួយចំនួនទៀតនៅខេត្តបាត់ដំបង និងក្រុងប៉ៃលិន ដោយសារខេត្តក្រុងទាំងនេះសំបូរគ្រាប់មីន ។ លោក ខឹម សោភ័ណ បាននិយាយថា ការបណ្តុះបណ្តាលមានរយៈពេល ៣ខែ រួចហើយឱ្យពួកគេធ្វើការតែម្តង ។ ប៉ុន្តែពេលពួកគេធ្វើការដំបូង CMAC បានបញ្ជូនបុគ្គលិកឱ្យធ្វើការជាមួយគេរយៈពេល ១ខែ ។ ពេលដែលពួកគាត់ឈប់ខ្លាចមីនហើយ ទើបយើងប្រគល់ឱ្យគាត់ដោះមីនដោយខ្លួនឯង ។ ដោយCMAC ប្រគល់ឧបករណ៍រាវមីន និងឧបករណ៍ផ្សេងៗទៀតដល់ពួកគេដូចបុគ្គលិក CMAC អីចឹងដែរ ។ លោក ខឹម សោភ័ណ បាននិយាយឱ្យដឹងថា គំរោងបណ្តុះបណ្តាលប្រជាពលរដ្ឋក្រីក្រឱ្យចេះដោះមីននេះ គឺយើងជ្រើសរើសយកប្រជាពលរដ្ឋដែលក្រីក្របំផុតក្នុងភូមិ ដូចជាមិនមានដីធ្លី មានដីតិច និងប្រជាពលរដ្ឋដែលមានអ្នកពិការនៅក្នុងគ្រួសារ ។ ប៉ុន្តែផ្តោតសំខាន់ទៅលើស្ត្រី ហើយគំរោងនេះ ប្រសិនបើគាត់ដោះមីនក្នុងភូមិហើយ ដីដែលគាត់ដោះមីននោះ យើងនឹងគ្រោងចែកឱ្យពួកគាត់តែម្តង នៅពេលដែលគាត់សំរាកពីការងារ ព្រោះគំរោងនេះមានរយៈពេល ២-៣ឆ្នាំ ប៉ុណ្ណោះ ។

លោកបានបន្តថា គំរោងនេះមានសារសំខាន់ណាស់ចំពោះ CMAC ក្នុងការចូលរួមចំណែកបោសសំអាតមីននៅតាមសហគមន៍ដោយចំណាយតិចតែទទួលបានលទ្ធផលច្រើន ។ មានន័យថា គំរោងនេះចំណាយក្នុងមួយខែប្រមាណតែ៤.៥០០ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងកងអនុសេនាតូចរបស់CMAC ចំណាយ ៧.៥០០ដុល្លារអាមេរិកក្នុងមួយខែ ដោយផ្ទៃដីដោះមីនមានប្រហាក់ប្រហែលគ្នា ។

ក្រៅពីនេះ យើងអាចជួយរកការងារធ្វើឱ្យប្រជាពលរដ្ឋក្រីក្រផងដែរ ពិសេសជួយលើកកំពស់ជីវភាពរស់នៅប្រចាំថ្ងៃ និងបានទទួលដីសំរាប់ប្រកបមុខរបរធ្វើស្រែចំការជា ដើម ។/

## សាលាក្រុងបើកការដ្ឋានចាក់កៅស៊ូផ្លូវ ២ខ្សែ ក្នុងសង្កាត់ផ្សារដេប៉ូទី៣

*លោក សួស សរិត AKP ភ្នំពេញ*

ផ្លូវលេខ២២១ និង២៣៣ ក្នុងសង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក ត្រូវបានសាលាក្រុងបើកការដ្ឋានជួសជុលកាលពីថ្ងៃ ២០ កញ្ញា ដោយចាក់កៅស៊ូ DBS ។ ផ្លូវ ២ខ្សែនេះ មានផ្ទៃក្រឡាសរុប ៤.៣០៧ម៉ែត្រការ៉េ ត្រូវចំណាយថវិកាសាលាក្រុងសរុបអស់ ៣០.១៤៩ដុល្លារអាមេរិក ។

ឯកឧត្តម កែប ជុតិមា អភិបាលក្រុង បានមានប្រសាសន៍ក្នុងឱកាសបើកការដ្ឋាននេះថា សាលាក្រុងបានជួយកសាងផ្លូវក្នុងខណ្ឌទួលគោលចំនួន ១៦ខ្សែហើយ ក្នុងនោះ មានផ្លូវចាក់បេទីមចំនួន ៣ខ្សែ និងផ្លូវចាក់កៅស៊ូ DBST បានចំនួន១៣ខ្សែ ។ ឯកឧត្តម បន្តទៀតថា ការរៀបចំអភិវឌ្ឍន៍មូលដ្ឋាន គឺជាចំណុចចម្បងនៃគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលដែលមានសម្តេច ហ៊ុន សែន ជាប្រមុខដឹកនាំ ។ ដោយសាលាក្រុងមើលឃើញថា ចរាចរក្នុងក្រុងសព្វថ្ងៃចេះតែចង្អៀតទៅៗ ហើយផ្លូវក្នុងក្រុងមួយចំនួននៅជាផ្លូវដីនៅឡើយ ពុំបានឆ្លើយតបទៅនិងតម្រូវការនៃចរាចររបស់បងប្អូមយើងនៅឡើយ ។ ការស្ថាបនាផ្លូវលេខ២២១ និង២៣៣ ក្នុងសង្កាត់ផ្សារដេប៉ូទី៣នេះ គឺមានសារសំខាន់ ដោយយើងអាចបញ្ចៀសចរាចរ និងបន្ថយការកកស្ទះលើមហាវិថីនានា ពិសេសមហាវិថីសហព័ន្ធរុស្ស៊ី ។

លោក សេង រតនៈ អភិបាលខណ្ឌទួលគោល បញ្ជាក់ឱ្យដឹងថា ៖ ការស្ថាបនាផ្លូវនាថ្ងៃនេះ គឺប្រភេទ DBST ។ ផ្លូវលេខ២២១ ចាប់ពីមហាវិថីសហព័ន្ធរុស្ស៊ីដល់ផ្លូវ១២២ មានប្រវែង ២៩៨ម៉ែត្រ ទទឹង ៧,៥០ម៉ែត្រ មានផ្ទៃក្រឡា ២.២៣៩ម៉ែត្រការ៉េ តម្លៃ ១៥.៦៤៥ដុល្លារអាមេរិក ។

ផ្លូវលេខ២៣៣ ចាប់ពីមហាវិថីសហព័ន្ធរុស្ស៊ីដល់មហាវិថីកម្ពុជាក្រោម មានប្រវែង ២៩៦ម៉ែត្រ ទទឹង ៧ម៉ែត្រ មានផ្ទៃក្រឡា ២.០៧២ម៉ែត្រការ៉េ តម្លៃ ១៤.៥០៤ដុល្លារអាមេរិក ។ ការដ្ឋានទាំងពីរនេះ ត្រូវបានប្រគល់ឱ្យក្រុមហ៊ុន គឹម ហាប់ ជាអ្នកអនុវត្តការងារ ។

លោកអភិបាលខ័ណ្ឌទួលគោក ក៏បានសំណូមពរចំពោះបងប្អូនប្រជាពលរដ្ឋដែលរស់នៅសងខាងផ្លូវនេះ ដែលមិនទាន់បានតបណ្តាញទឹកចូលផ្ទះ ត្រូវរួសរាន់រៀបចំតឱ្យហើយមុនការស្ថាបនាផ្លូវនេះ ។ នៅពេលផ្លូវនេះស្ថាបនារួច សូមឱ្យបងប្អូនប្រជាពលរដ្ឋជួយថែរក្សាផ្លូវនេះឱ្យបានគង់វង់យូរអង្វែង ។/

## ការអនុវត្តន៍កម្មវិធីបង្ការ និងថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍

*លោក សំ សាម៉ន AKP ភ្នំពេញ*

ឯកឧត្តម ម៉ម ប៊ុនហេង មានប្រសាសន៍ថា ៖ កិច្ចប្រជុំស្តីពីការសំរបសំរួលការអនុវត្តន៍កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍រវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ និងបណ្តាខេត្តក្រុងនេះ ត្រូវធ្វើអោយបានយ៉ាងតិចពីរដងក្នុងមួយឆ្នាំក្នុងគោលបំណងផ្តល់នូវវេទិការមួយសំរាប់ពិនិត្យមើលឡើងវិញ និងការពិភាក្សាអំពីការវិវត្តន៍ទៅមុខ នៃការអនុវត្តន៍សកម្មភាពស្វែងរកដំណោះស្រាយលើរាល់

បញ្ហាដែលទាក់ទងទៅនឹងសកម្មភាពទាំងអស់របស់មជ្ឈមណ្ឌលជាតិ ដូចជាការអនុវត្តន៍សកម្មភាព ការសំរបសំរួលការងារ ការគ្រប់គ្រងការងារ និងបញ្ហាហិរញ្ញកិច្ច និងធ្វើការកែសំរួលគំរោងផែនការសកម្មភាពប្រចាំឆ្នាំ ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត បើសិនជាចាំបាច់ ។

ឯកឧត្តម មានប្រសាសន៍ក្នុងពិធីបើកកិច្ចប្រជុំសំរបសំរួលស្តីពីការអនុវត្តន៍កម្មវិធីបង្ការ និងថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ នាព្រឹកថ្ងៃទី២០ កញ្ញា ឆ្នាំ២០០៩ នៅវិទ្យាស្ថានសុខភាពសាធារណៈ រៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ ។

ឯកឧត្តម មានប្រសាសន៍ថា : កត្តាសំខាន់មួយទៀតរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគក្នុងការអនុវត្តន៍សកម្មភាព គឺផ្តល់នូវការគាំទ្រ និងសហការណ៍យ៉ាងជិតស្និទ្ធជាមួយនឹងបណ្តាខេត្ត-ក្រុងទាំងអស់ ។ មន្ទីរសុខាភិបាលខេត្ត-ក្រុង ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកទាំងអស់ គឺជាកន្លែងដែលផ្តល់សេវាសុខាភិបាលពិតប្រាកដ គឺមិនមែននៅក្រសួងសុខាភិបាល ឬមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគទេ ។ ដូច្នេះការផ្តល់គាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកា ការផ្តល់នូវភាពជឿទុកចិត្ត និងមានទំនាក់ទំនងល្អរវាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមន្ត្រីថ្នាក់ខេត្ត-ក្រុងទាំងអស់ក្នុងការអនុវត្តន៍សកម្មភាព គឺជាកត្តាមួយដែលគួរអោយកោតសរសើរ ។

លោកវេជ្ជបណ្ឌិត Brad Hersh ប្រធាន US/CDC Global AIDS Program ប្រចាំកម្ពុជា មានប្រសាសន៍ថា: ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលបានចាត់ទុកថាបានទទួលជោគជ័យលើការបង្ការការរីករាលដាលនៃមេរោគអេដស៍ ។ ប៉ុន្តែដោយក្រឡេកមើលទៅលើលទ្ធផលអង្កេតឈាមឆ្នាំ ២០០៣ អត្រាប្រេវ៉ាឡង់ស្មើនឹង ១,៩% ដែលជាអត្រាមួយខ្ពស់ជាងគេនៅក្នុងតំបន់ ។ ហេតុនេះយើងត្រូវបន្តការខិតខំប្រឹងប្រែងរបស់យើងលើការពង្រឹងភាពជាដៃគូរ វាងស្ថាប័នរដ្ឋ និងសង្គមស៊ីវិល ហើយនិងរួមគ្នាប្រយុទ្ធប្រឆាំងនឹងការរាតត្បាតរបស់ជំងឺនេះ ។ យើងត្រូវការកម្មវិធីដែលផ្តោតលើគ្រួសារនិងស្ត្រីមានផ្ទៃពោះដែលការចម្លងមេរោគអេដស៍ចំបងនាបច្ចុប្បន្ននេះ កើតឡើងពីប្តីទៅប្រពន្ធ និងពីម្តាយទៅទារកក្នុងផ្ទៃ ។ យើងត្រូវការកម្មវិធីដោយផ្តោតទៅលើ លើកកំពស់គុណភាពជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍តាមរយៈការផ្តល់ឱសថប្រឆាំងនឹងមេរោគអេដស៍ ការបង្ការ និងការព្យាបាលជំងឺឱកាសនិយមនៅប្រព័ន្ធសុខាភិបាលមួយដ៏សមស្រប ដើម្បីធានាថាសេវាទាំងនេះត្រូវបានចូលមកប្រើប្រាស់ និងមានការពេញចិត្តពីអ្នកប្រើប្រាស់ ។/

**គណៈនាយកសាលារៀនខេត្តតាកែវ**

**អំពាវនាវឱ្យប្រជាពលរដ្ឋនាំកូនអាយុគ្រប់មកចុះឈ្មោះចូលរៀន**

*លោក កែវ សំអឿន AKP តាកែវ*

គណៈនាយកសាលារៀនខេត្តតាកែវ បានអំពាវនាវឱ្យអាជ្ញាធរជួយជំរុញប្រជាពលរដ្ឋនាំកូនគ្រប់អាយុមកចុះឈ្មោះចូលរៀនតាមកាលបរិច្ឆេទនៃការទទួលចុះឈ្មោះកុមារចូលរៀននៅថ្នាក់មត្តេយ្យ នឹងថ្នាក់ទី១ បឋមសិក្សា ដែលនឹងបញ្ចប់ត្រឹមថ្ងៃទី២២ ខែកញ្ញា នេះ ។ ទោះជាយ៉ាងណាក្តី គ្រប់សាលាបឋមសិក្សាទាំងអស់នៅតែខិតខំបន្តទទួលចុះឈ្មោះកុមារចូលរៀនដោយក្តីរីករាយ ដោយមិនបាច់បង់វិភាគទានឬតម្លៃអ្វីឡើយ ។

លោក រស់ សារួន នាយកសាលាបឋមសិក្សាកម្រង ត្រាំខ្នារ បានមានប្រសាសន៍ថា ៖ សាលារៀនរបស់លោកមិនសូវព្រួយបារម្ភអំពីរឿងគ្មានកុមារមកចុះឈ្មោះរៀនឡើយ ដោយសារតែតំបន់ជុំវិញសាលារៀនរបស់លោកមានប្រជាពលរដ្ឋរស់នៅចំណូលថ្មីចូលមករស់នៅជាច្រើនគ្រួសារ ។ ប៉ុន្តែទោះជាយ៉ាងបែបនេះក្តី លោកនៅតែសហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមានកូនអាយុ៦ឆ្នាំ មកចុះឈ្មោះចូលរៀន ។ បើមិនធ្វើដូច្នេះទេ មាតាបិតា អាណាព្យាបាលសិស្សមួយចំនួនភ្លេចនាំកូនមកចុះឈ្មោះចូលរៀន ដោយសារតែរវល់ក្នុងការប្រកបមុខរបរផ្សេងៗ ពិសេសការធ្វើស្រែដែលកំពុងមមាញឹក ។ លោកបានបន្តទៀតថា កាលបរិច្ឆេទទទួលពាក្យចុះឈ្មោះកុមារចូលរៀនថ្នាក់មត្តេយ្យ និងថ្នាក់ទី១ បឋមសិក្សាកាលពីថ្ងៃទី១៣ ដល់ថ្ងៃទី២២ កញ្ញា បានជិតផុតកំណត់ហើយ ប៉ុន្តែសាលារៀនរបស់លោកនៅតែបន្តទទួលចុះឈ្មោះកុមារឱ្យចូលរៀនបន្តបន្ទាប់ដដែល ។ បើសិនជាពួកគាត់ពន្យារពេលមិននាំកូនដែលមានអាយុ ៦ឆ្នាំ មកចុះឈ្មោះចូលរៀនឱ្យទាន់ក្នុងបវេសនកាលនេះទេ នឹងធ្វើឱ្យការសិក្សាកូនរបស់គាត់រៀនមិនទាន់កម្មវិធីសិក្សាឡើយ ដែលជាហេតុបង្កការលំបាកដល់លោកគ្រូ អ្នកគ្រូ ។

លោកនាយកសាលា ត្រាំខ្នារ បានបញ្ជាក់ឱ្យដឹងទៀតថា ឆ្នាំសិក្សាថ្មីនេះ សាលារៀនរបស់លោកទទួលបានកុមារចុះឈ្មោះចូលរៀនច្រើនជាងបណ្តាឆ្នាំកន្លងមក ដូច្នេះបញ្ហាដែលត្រូវដោះស្រាយ គឺត្រូវកសាងអគារសិក្សា បន្ថែមគ្រូ និងសម្ភារៈសិក្សាឱ្យបានគ្រប់គ្រាន់ ស្របតាមនិយាមគរុកោសល្យ ។/